ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# អនុស្សរណៈនៃការយោគយល់គ្នា

រវាង

អង្គការការីតាស ស្វីស

និង

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស

ស្តីពី

វិធីសាស្ត្រគ្រប់ជ្រុងជ្រោយក្នុងការទប់ស្កាត់ ការការពារ និងសមាហរណកម្ម

ចំពោះកុមារ  យុវជន និងស្ត្រីវ័យក្មេងកម្ពុជាដែលងាយរងគ្រោះ/រងគ្រោះ

ពីការចំណាកស្រុកអសុវត្ថិភាព និងការជួញដូរមនុស្ស

២០១៩ - ២០២១

# សង្ខេបគម្រោង

| | |
|---|---|
| ឈ្មោះអង្គការ: | ការីតាស ស្វីស |
| ប្រភេទអង្គការ: | អង្គការអន្តរជាតិ មិនមែនរដ្ឋាភិបាល |
| អាសយដ្ឋាន: | បន្ទប់ បេ០២ ផ្ទះ៥៦ ផ្លូវ៣០៦ សង្កាត់បឹងកេងកង១ ខណ្ឌចំការមន រាជធានីភ្នំពេញ ប្រទេសកម្ពុជា |
| លេខទូរស័ព្ទទំនាក់ទំនង: | (៨៥៥) ១២៩៨៥៧៩៦ |
| អ៊ីម៉ែល: | cambodia@caritas.ch |
| ឈ្មោះគម្រោងសកម្មភាព: | ចំណាកស្រុកប្រកបដោយសុវត្ថិភាព និងការប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស |
| លេខកូដគម្រោង: | p_170091 ការទប់ស្កាត់ការជួញដូរមនុស្ស និងមជ្ឈមណ្ឌលអភិវឌ្ឍន៍ជំនាញវិជ្ជាជីវៈ ដល់ស្ត្រីដែលងាយរងគ្រោះ<br>p_180002 វិធីសាស្ត្រទូទៅក្នុងការផ្តល់សេវាដល់កុមារកម្ពុជា និងយុវជន រួចផុតពីការចំណាកស្រុកអសុវត្ថិភាព និងអ្នកងាយរងគ្រោះដោយការជួញដូរមនុស្ស |
| ទីតាំងគម្រោង: | ខេត្តព្រៃវែង ខេត្តបាត់ដំបង និងខេត្តបន្ទាយមានជ័យ |
| ដៃគូអនុវត្តគម្រោង: | អង្គការដំណក់ទឹក និង អង្គការ ការីតាស កម្ពុជា |
| ថវិកាអនុវត្តគម្រោង: | 1,500,000 ដុល្លារសហរដ្ឋអាមេរិក |
| កាលបរិច្ឆេទចាប់ផ្តើម: | ថ្ងៃទី០១ ខែមករា ឆ្នាំ ២០១៩ |
| កាលបរិច្ឆេទបញ្ចប់: | ថ្ងៃទី៣១ ខែ ធ្នូ ឆ្នាំ ២០២១ |
| ចំនួនបុគ្គលិកខ្មែរ: | ២៥នាក់ (ស្រី ១១នាក់) |
| ចំនួនបុគ្គលិកបរទេស: | ០២នាក់ |
| អ្នកគ្រប់គ្រងគម្រោង: | លោក ខាំ ស៊ីងួន |

# អនុស្សរណៈនៃការយោគយល់គ្នា

# រវាង

# អង្គការការីតាស ស្វីស

# និង

# គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស

# ស្តីពី

# វិធីសាស្ត្រគ្រប់ជ្រុងជ្រោយក្នុងការទប់ស្កាត់ ការការពារ និងសមាហរណកម្មចំពោះកុមារ យុវជន និងស្ត្រី វ័យក្មេងកម្ពុជាដែលងាយរងគ្រោះ/រងគ្រោះ ពីការចំណាកស្រុកអសុវត្ថិភាព និងការជួញដូរមនុស្ស

## ផ្នែកទី១

## បុព្វកថា

**ដោយហេតុថា៖** គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានសំដែងនូវបំណងប្រាថ្នា ដូចមានចែងក្នុងអនុស្សរណៈ នៃការយោគយល់គ្នានេះថា អង្គការការីតាស ស្វីស បាន រួមចំណែកក្នុងការទប់ស្កាត់ ការកាពារ និងការធ្វើសមាហរណកម្ម ចំណាកស្រុក និង ការប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស ។

**ដោយហេតុថា៖** គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និង អង្គការការីតាស ស្វីស ត្រូវ សហការគ្នាក្នុងការបង្ការទប់ស្កាត់ ការការពារ និងការធ្វើសមាហរណកម្ម ចំណាកស្រុក និងការប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស តាមរយៈកិច្ចព្រមព្រៀងក្នុងភាពជាដៃគូដូចមាន ចែងក្នុងអនុស្សរណៈនៃការយោគយល់គ្នា។

**ដោយហេតុថា៖** គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និង អង្គការការីតាស ស្វីស បាន យល់ព្រមសហការដូចមានចែងសកម្មភាពជាក់ស្តែងដូចខាងក្រោម៖

**១) គោលដៅគម្រោង៖**

រួមចំណែកកាត់បន្ថយការជួញដូរមនុស្ស និងលើកស្ទួយការធ្វើចំណាកស្រុកដោយសុវត្ថិភាពតាមរយៈ ការទប់ស្កាត់ ការការពារ និងការធ្វើសមាហរណកម្ម ។

## ២) គម្រោងសកម្មភាព៖

**ចំណាកស្រុក** គឺជាកម្មវិធីយុទ្ធសាស្ត្រ នៃកិច្ចសហប្រតិបត្តិការអន្តរជាតិរបស់ អង្គការការីតាស ស្វីស ដែលមានទិសដៅ៖ (១).បញ្ចប់ការជួញដូរមនុស្ស (២).លក្ខខណ្ឌការងារ និងរស់នៅសមរម្យ (៣). ប្រាក់ពីការងារចំណាកស្រុកដើម្បីអភិវឌ្ឍ ។ យុទ្ធសាស្ត្រនេះត្រូវនឹងកម្មវិធីរបស់អង្គការការីតាស ស្វីស ប្រចាំប្រទេសកម្ពុជាដែលធ្លាប់បានជួយគាំទ្រដល់អង្គការដៃគូពីរ ក្នុងការទប់ស្កាត់ការជួញដូរមនុស្ស និងការពារជនរងគ្រោះក្នុងរយៈពេលពីរ បីឆ្នាំកន្លងមកហើយគឺ៖

- **ការីតាសកម្ពុជា** ៖ ការទប់ស្កាត់ការជួញដូរមនុស្ស និងមជ្ឈមណ្ឌលអភិវឌ្ឍន៍ជំនាញវិជ្ជាជីវៈដល់ស្ត្រីដែលងាយរងគ្រោះ ។
- **អង្គការដំណក់ទឹក** ៖ វិធីសាស្ត្រទូទៅក្នុងការផ្តល់សេវាដល់កុមារកម្ពុជា និងយុវជនរួចផុតពីការចំណាកស្រុកអសុវត្ថិភាព និងអ្នកងាយរងគ្រោះដោយការជួញដូរមនុស្ស ។

## ៣) គោលបំណងជាក់លាក់គម្រោង៖

ដើម្បីបង្កើតបរិយាកាសសុវត្ថិភាពសម្រាប់កុមារដែលងាយរងគ្រោះ យុវជន និងស្ត្រីនៅក្នុងតំបន់គោលដៅតាមរយៈវិធានការទប់ស្កាត់ និងការឆ្លើយតបគ្រប់គ្រាន់ទៅនឹងតម្រូវការរបស់ជនរងគ្រោះដោយការជួញដូរ និងរំលោភ។

## ៤) លទ្ធផលគម្រោង៖

១. ការទប់ស្កាត់៖ ដើម្បីផ្តល់ព័ត៌មានអំពីការចំណាកស្រុកប្រកបដោយសុវត្ថិភាព និងមធ្យោបាយដើម្បីទប់ស្កាត់តាមរយៈការផ្សព្វផ្សាយដោយផ្ទាល់ក្នុងសហគមន៍ដល់កុមារ យុវជនដែលប្រឈមប្រថាន និងស្ត្រីវ័យក្មេង និងបងប្អូនរបស់គេ តាមរយៈយុទ្ធនាការលើកកម្ពស់ការយល់ដឹង ការកសាងសមត្ថភាព ការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ និងការស្វែងរកការងារធ្វើ។ ក្រុមគោលដៅមានចំនួន ៣៥,០០០នាក់។

២. ការការពារ៖ ផ្តល់ការគាំពារ និងសេវាចាំបាច់ និងបន្ទាន់ក៏ដូចជាសេវាបញ្ជូនជនរងគ្រោះដើម្បីទទួលបាននូវតម្រូវការជាមូលដ្ឋាន ការស្តារ និងការត្រៀមរៀបចំជាមុនសម្រាប់សមាហរណកម្មដល់ជនរងគ្រោះនៃការជួញដូរមនុស្ស និងរាល់ទម្រង់នៃអំពើហិង្សា។ ក្រុមគោលដៅមានចំនួន ៥០០នាក់ទទួលបានសេវាគាំទ្រ។

៣. ការធ្វើសមាហរណកម្ម៖ ដើម្បីផ្តល់សេវាសមាហរណកម្មចំពោះជនរងគ្រោះកុមារ យុវជន និងស្ត្រីវ័យក្មេងទៅគ្រួសារ សហគមន៍ និងសង្គម តាមរយៈការអប់រំ ការរកប្រាក់ចំណូល និងការផ្តល់ជំនាញការបណ្តុះបណ្តាលវិជ្ជាជីវៈ និងសេវារកការងារធ្វើ។ ក្រុមគោលដៅមានចំនួន ៧៥០នាក់ ។

៤. ការសម្របសម្រួលៈ ពង្រឹងសមត្ថភាពស្ថាប័ន និងការសម្របសម្រួលរដ្ឋបាលថ្នាក់ក្រោមជាតិ និង រចនាសម្ព័ន្ធសហគមន៍ដើម្បីគាំទ្រលទ្ធផលទាំងបីខាងលើ ។

## ផ្នែកទី២

### ការទទួលខុសត្រូវរបស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស

**មាត្រា១ៈ** គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស គាំទ្របេសកកម្ម អង្គការការីតាសស្វីស និងអង្គការដៃគូ ក្នុងការបំពេញការងាររបស់ខ្លួនដោយអនុវត្តស្របតាមច្បាប់ នៃព្រះរាជាណាចក្រកម្ពុជា។

**មាត្រា២ៈ** សម្របសម្រួលជាមួយ គណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សថ្នាក់ក្រោមជាតិ ដើម្បីចូលរួមសហការសកម្មភាពនានារបស់អង្គការការីតាសស្វីស និងអង្គការដៃគូ ដើម្បីសម្រេចលទ្ធផលដូចមានចែងខាងលើ។

**មាត្រា៣ៈ** ដឹកនាំកិច្ចប្រជុំពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធនៅថ្នាក់ខេត្តដូចជាៈ ខេត្តបន្ទាយមានជ័យ ខេត្តបាត់ដំបង ខេត្តប៉ៃលិន ខេត្តសៀមរាប និងខេត្តព្រៃវែង ដើម្បីសម្របសម្រួលអ្នកពាក់ព័ន្ធក្នុងការដោះស្រាយ ការចំណាកស្រុកដោយប្រថុយប្រថាន និងការប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស។

**មាត្រា៤ៈ** ធានាថាអោយមានការចែករំលែកព័ត៌មាន និងបទពិសោធន៍ល្អ និងលទ្ធផលសម្រេចបាននៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដើម្បីជាផលប្រយោជន៍នៃការទំនាក់ទំនងនិងលើកស្ទួយប្រសិទ្ធភាពការងារក្នុងការទប់ស្កាត់ ការការពារ និងសមាហរណកម្មអ្នកចំណាកស្រុកដែលងាយរងគ្រោះ និងកុមារដែលត្រូវបានគេជួញដូរ។

## ផ្នែកទី៣

### ការទទួលខុសត្រូវរបស់អង្គការការីតាស ស្វីស

**មាត្រា៥ៈ** អង្គការការីតាសស្វីស គ្រប់គ្រងថវិកាកម្មវិធី សម្រាប់ការអនុវត្តសកម្មភាពរបស់គម្រោងឲ្យមានប្រសិទ្ធភាព និងប្រសិទ្ធផលចំគោលដៅ និងត្រូវគោរពឲ្យបានខ្ជាប់ខ្ជួននូវច្បាប់ និងបទបញ្ញត្តិទាំងឡាយ របស់ព្រះរាជាណាចក្រកម្ពុជា និងមិនអនុញ្ញាតឲ្យបុគ្គលិក និងអង្គការដៃគូរបស់ខ្លួនចូលរួមនូវរាល់សកម្មភាពទាំងឡាយណា ដែលអាចប៉ះពាល់ដល់សុវត្ថិភាព ស្ថិរភាព និងសណ្តាប់ធ្នាប់សង្គម ឬសកម្មភាពដទៃទៀត ដែលអាចបង្កអន្តរាយដល់សន្តិសុខជាតិ ឯកភាពជាតិ វប្បធម៌ និងប្រពៃណីរបស់ប្រជាជនកម្ពុជា ។

**មាត្រា៦៖** អង្គការការីតាសស្វីស ប្រតិបត្តិនូវរាល់សកម្មភាពគាំទ្រដល់ការការពារទេសន្តរប្រវេសន៍ការងារ ដល់អ្នកងាយរងគ្រោះដោយចំណាកស្រុក និងកុមារប្រឈមនឹងការជួញដូរមនុស្ស ដូចមានក្នុងផែនការសកម្មភាព គោលនយោបាយ និងគោលការណ៍នៃកិច្ចសហប្រតិបត្តិការ។

**មាត្រា៧៖** អង្គការការីតាស ស្វីស ត្រូវពង្រឹងភាពជាដៃគូរវាង គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នូវរាល់សកម្មភាព និងផ្តល់ព័ត៌មានដល់ក្រុមគោលដៅ។ ការផ្លាស់ប្តូរព័ត៌មានពីថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិទាក់ទងនឹងការជួញដូរមនុស្ស និងការចំណាកស្រុកប្រកបដោយសុវត្ថិភាព និងផ្តល់របាយការណ៍ប្រចាំ ឆមាស និងឆ្នាំ តាមទម្រង់របាយការណ៍របស់រដ្ឋាភិបាលទៅកាន់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស អំពីសកម្មភាពអនុវត្ត លទ្ធផលសម្រេចបាន បញ្ហាប្រឈម ចំណុចរៀនសូត្រ និងការអនុវត្តល្អ ។

**មាត្រា៨៖** អង្គការការីតាសស្វីស គួរតែផ្តោតលើសកម្មភាពទាក់ទងនឹងការចំណាកស្រុកប្រកបដោយសុវត្ថិភាព និងប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស។ ត្រូវចៀសវាងរាល់សកម្មភាពទាក់ទងនឹងនយោបាយ និងចំណេញពីសកម្មភាពការងារចំណាកស្រុក និងការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ។

**មាត្រា៩៖** អង្គការការីតាសស្វីស ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរដល់ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ស្តីពីការផ្លាស់ប្តូរណាមួយទាក់ទងនឹងអាសយដ្ឋាន អ្នកតំណាង និងនាយកគម្រោងដែលបានចាត់តាំង ។

## ផ្នែកទី៤

## អវសានបញ្ញត្តិ

**មាត្រា១០៖** ភាគីទាំងពីរយល់ព្រមចាត់តាំងជនបង្គោលដើម្បីទំនាក់ទំនង និងអនុវត្តការងារ នៃអនុស្សរណៈនេះ។ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នឹងចាត់តាំងលោក-លោកស្រី [illegible]......តួនាទី អគ្គលេខាធិការរង...... ទូរស័ព្ទទំនាក់ទំនង 012 741158 អាសយដ្ឋាន អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ...... និងអង្គការការីតាស ស្វីស នឹងចាត់តាំង លោក ខាំ ស៊ីងួន អ្នកគ្រប់គ្រងកម្មវិធី ទូរស័ព្ទលេខ ៨៥៥១២៩៨៥៧៩៦ និងអ៊ីម៉ែល syngoun@caritas.ch

**មាត្រា១១៖** រាល់វិវាទរវាងគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអង្គការការីតាសស្វីស ទាក់ទងទៅនឹងការអនុវត្ត ឬការបកស្រាយអនុស្សរណៈនេះ នឹងត្រូវបានដោះស្រាយតាមរយៈការចរចាដោយសន្តិវិធីរវាងភាគីទាំងពីរ។

**មាត្រា១២៖** អនុស្សរណៈនៃការយោគយល់គ្នានេះ អាចបញ្ចប់ដោយភាគីណាមួយក៏បាន គឺបន្ទាប់ពី៦០ថ្ងៃ ដែលភាគីនោះផ្តល់សេចក្តីជូនដំណឹងជាលាយលក្ខណ៍អក្សរបញ្ជូនទៅភាគីម្ខាងទៀត ។

**មាត្រា១៣៖** អនុស្សរណៈនេះចូលជាធរមាននៅពេលដែលភាគីទាំងពីរចុះហត្ថលេខា និងមានសុពលភាពរយៈពេល៣ឆ្នាំ ហើយនឹងត្រូវបន្តសុពលភាពដោយមានការយល់ព្រមពីភាគីទាំងពីរ។

**មាត្រា១៤៖** អនុស្សរណៈនេះធ្វើឡើងជាពីរច្បាប់ដើម ជាភាសាខ្មែរ និងភាសាអង់គ្លេស ដោយអត្ថបទទាំងពីរមានតម្លៃស្មើគ្នា។

ថ្ងៃ...ចន្ទ ៨ រោច...ខែ...អស្សុជ.....ឆ្នាំកុរ ឯកស័ក ព.ស២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី...២១....ខែ..តុលា......ឆ្នាំ២០១៩

**តំណាងគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស**

អនុប្រធានអចិន្ត្រៃយ៍

**ជូ ប៊ុនអេង**

**តំណាងអង្គការការីតាស ស្វីស**

នាយកប្រចាំប្រទេស

Switzerland Suiza CARITAS Schweiz 6002 Luzern Suisse Svizzera

**ម៉ាក ភ្លូកល័រ**

ប្រធានកម្មវិធី

**ខាំ ស៊ីខួន**

Kingdom of Cambodia

Nation Religion King

# Memorandum of Understanding

**Between**

**Caritas Switzerland (CaCH)**

**And**

**National Committee for Counter Trafficking**

**On**

**A Comprehensive Approach on Prevention, Protection and Reintegration of Cambodian Children, Youth and Young Women who are at Risk or Victim of Unsafe Migration or Human Trafficking**

**2019-2021**

**Project summary**

| | |
|---|---|
| Name of organization: | Caritas Switzerland (CaCH) |
| Type of organization: | International Non-Government Organization |
| Address: | Apartment room B02, #56, Street 306, Sangkat Boeng Keng Kang I, Khan Chamkamorn, Phnom Penh, Cambodia. |
| Telephone: | 855-12985796 |
| Email: | cambodia@caritas.ch |
| Name of project: | Safe Migration & Anti-Human Trafficking |
| Code of project: | P_170091 Prevention of Human Trafficking and Vocational Skills Development Center for Vulnerable Women<br>P_180002 A Comprehensive Approach to Service Delivery for Cambodian Children and Youth Recovering from or Vulnerable to Human Trafficking |
| Project location: | Prey Veng, Battambang and Banteay Meanchey |
| Project partner: | Damnok Toek (DT) and Caritas Cambodia (CaC) |
| Budget: | USD 1,500,000 |
| Starting date: | 1st January 2019 |
| Ending date: | 31st December 2021 |
| Number of Cambodian Staff: | 25 people (11 females) |
| Number of Foreign Staff: | 02 people |
| Project Manager: | Mr. Kham Syngoun |

**Memorandum of Understanding**

**Between**

**Caritas Switzerland (CaCH)**

**And**

**National Committee for Counter Trafficking**

**On**

**A Comprehensive Approach on Prevention, Protection and Reintegration of Cambodian Children, Youth and Young Women who are at Risk or Victim of Unsafe Migration or Human Trafficking**

## Section I

## Preamble

**Whereas:** National Committee for Counter Trafficking has expressed its desire as stated in the MoU that Caritas Switzerland (CaCH) has contributed to prevention, protection and re-integration of migration and anti-human trafficking.

**Whereas:** National Committee for Counter Trafficking and Caritas Switzerland (CaCH) need to co-operate in prevention, protection and re-integration of migration and anti-human trafficking through legally partnership agreement as provision in the Memorandum of Understanding.

**Whereas:** NOW THEREFORE, National Committee for Counter Trafficking and Caritas Switzerland (CaCH) have agreed to collaborate as follows:

1) **General Objective**

Contribute to a reduction of human trafficking and promote safe-migration through prevention, protection and re-integration.

2) **Project Description**

The "Migration" is one the CaCH's International Cooperation Strategy, which strategic outcomes encompass (1) ending human trafficking, (2) decent living and working conditions, and (3) remittances for development. The strategy fittingly accommodates CaCH programme in Cambodia, where we have supported two Partner Organizations active in prevention of trafficking in persons and protection of victims over the past few years:

- **Caritas Cambodia**: Prevention of Human Trafficking and Vocational Skills Development Center for Vulnerable Women);
- **Damnoek Toek**: A Comprehensive Approach to Service Delivery for Cambodian Children and Youth Recovering from or Vulnerable to Human Trafficking.

**3) Specific Objective**

To create a safe environment for vulnerable children, youth and women in the project area through preventive measures and adequate response to the needs of victims of trafficking, exploitation and abuse.

**4) The project outcomes**

1. **Prevention** - To provide information on safe migration practices and means to prevent trafficking through community-based outreach targeting children, youth and young women at risk and their relatives, with awareness raising campaigns and capacity building and alternative vocation skills training and job placement. Annually target 35,000 beneficiaries reached.
2. **Protection** - To provide immediate and emergency care and effective referrals for basic needs, rehabilitate and reintegration preparedness victims of human trafficking and other forms of violence. Annually target 500 received services support.
3. **Reintegration** - To provide services to reintegrate victim children, youth and young women into family, community and society through education, income generation, and vocational skill training & job placement services. Annually target 750 beneficiaries.
4. **Coordination** - To strengthen institutional capacity and coordination of sub-national government and community structure to support 3 outcomes above.

## Section II

## The responsibilities of the National Committee for Counter Trafficking (NCCT)

**Article 1:** NCCT support the mission of Caritas Switzerland (CaCH) and its partners through their implementation according to the law of The Royal Government of Cambodia.

**Article 2:** Coordinate with NCCT Sub-national level to join and cooperate with The Caritas Switzerland (CaCH) and its partner activities to address outcome results above.

**Article 3:** Lead stakeholder consultation at provincial level (Banteay Meanchey, Battambang, Pailin, Siemreap and Prey Veng) for stakeholder coordination to address migration at risk and combat human trafficking.

**Article 4:** To ensure the information sharing regarding best practices and achievement results at both National and Sub-national level for the advantages of coordination and promoting the effective work in the prevention, protection and reintegration of vulnerable migrant and the trafficked children.

## Section III

### Caritas Switzerland (CaCH) has the responsibilities as follow:

**Article 5:** The Caritas Switzerland manage the program budget for the implementation of the program activities with the effectiveness and efficiency toward the project overall goal and outcome and must respect to the Royal Government of Cambodia law and not allow their staff and partner join any activities that affect to national security, unity, culture and tradition of Cambodian.

**Article 6:** The Caritas Switzerland is implementing the activities support to the protection of vulnerable migrant and at risk children of human trafficking as mentioned in the workplan, policies and the principle of cooperation.

**Article 7:** The Caritas Switzerland will strengthen the partnership between NCCT in all implementation of activities and provide the information to their target. For exchange of information from national level to sub-national level regarding Human Trafficking, safe migration and provide a Standard semester and annual report as per government reporting format to NCCT.

**Article 8:** The Caritas Switzerland should only engage in the all activities related to safe migration and anti-human trafficking purpose. And avoid linking with any activities that relate to politic, profit through migration and anti-human trafficking acts.

**Article 9:** The Caritas Switzerland should provide a written notice to NCCT on any change related to address, representative and project manager.

## Section IV

## Final Provision

**Article 10:** Both parties agree to assign focal person in order to smooth communication and implementation of the MoU. The NCCT is assign Mr/Ms RAN SEREYLEAKHENA, title Vice Secretary General contact address 012 771158 and CaCH is assign Mr. Kham Syngoun, Programme Manager, mobile phone: 855-12 985796 and e-mail: syngoun@caritas.ch.

**Article 11:** All conflict between NCCT and The Caritas Switzerland related to the implementation or interpretation this MoU will be addressed through negotiation in peacefully by both parties.

**Article 12:** This MoU should be terminated by each of party, after 60 days when any side provide the written notice to other side.

**Article 13:** The MoU will be affected from the date of signature and valid for 3 years and the extension of validity based on mutual agreement.

**Article 14:** This MOU is written in duplicate, in Khmer and English, both texts are equally authentic.

Done at Phnom Penh on 21st October 2019

| NCCT Representative | Caritas Switzerland Representative |
| --- | --- |
| ................................ | ................................ |
| **CHOU BUN ENG**<br>Permanent Vice Chairperson of NCCT | **Marc Gloekler, Country Director**<br>Country Representative |
| | ................................ |
| | **Syngoun Kham,**<br>Programme Manager |

CARITAS Schweiz Switzerland Suiza Svizzera Suisse 6002 Luzern